AFP

# ការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍

របៀបរាយការណ៍អំពីការគម្រាមនិងបំភិតបំភ័យពីបរទេស

FACTSHEET / April 2023

afp.gov.au

## អារម្ភកថា

ការជ្រៀតជ្រែកពីបរទេសគឺជាសកម្មភាពដែលអាចបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរដល់ប្រជាជន អធិបតេយ្យភាព និងសន្តិសុខអូស្ត្រាលី ហើយនិងបូរណភាពនៃស្ថាប័នជាតិទាំងឡាយរបស់យើង។ ការគម្រាមដែលមានលក្ខណៈជាការជ្រៀតជ្រែកពីបរទេសមិនមែនមានត្រឹមតែក្នុងមួយជ្រុងនៃសហគមន៍អូស្ត្រាលីឡើយ ហើយក៏មិនមែនប្រព្រឹត្តឡើងដោយរដ្ឋតែមួយប៉ុណ្ណោះដែរ។ រដ្ឋបរទេសដែលជាអ្នកប្រព្រឹត្តអំពើកោងកាច (ប្រទេសដែលធ្វើសកម្មភាពប្រឆាំងនិងប្រទេសដទៃ) កំពុងបង្កើតនិងប្រើងរកឱកាសដើម្បីជ្រៀតជ្រែកជាមួយអ្នកដែលមានតួនាទីជាអ្នកសម្រេចទាំងឡាយនៅប្រទេសអូស្ត្រាលីនៅគ្រប់ថ្នាក់ក្នុងរដ្ឋាភិបាល និងឆ្លងកាត់ផ្នែកមួយចំនួន រួមទាំងស្ថាប័នប្រជាធិបតេយ្យ សិក្សាធិការនិងស្រាវជ្រាវ ប្រព័ន្ធផ្សព្វផ្សាយនិងទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ហើយនិងជាសំខាន់ សហគមន៍ដែលមានវប្បធម៌និងភាសាចម្រុះរបស់យើង (CALD)។

## ការជ្រៀតជ្រែកពីបរទេសនៅក្នុងសហគមន៍

ការជ្រៀតជ្រែកពីបរទេសនៅក្នុងសហគមន៍ត្រូវបានគេឲ្យអត្ថន័យថាជាការគម្រាមនិងការបំភិតបំភ័យដែលមានការបញ្ជា មើលពីលើ ឬឧបត្ថមថវិកាដោយរដ្ឋាភិបាលបរទេសសំដៅទៅលើសហគមន៍ CALD ដើម្បីបង្ក្រាះថ្នាក់និងធ្វើឲ្យមានការប៉ះពាល់ដល់របៀបរស់នៅពហុវប្បធម៍របស់ប្រទេសអូស្ត្រាលី។ រដ្ឋាភិបាលបរទេសអាចជ្រៀតជ្រែកក្នុងសហគមន៍នានាដើម្បីគោលបំណងមួយចំនួន ៖

- ដើម្បីបំបិទមាត់កុំឲ្យគេទិទានគោលនយោបាយក្នុងនិងក្រៅប្រទេសរបស់រដ្ឋាភិបាលនោះ
- ដើម្បីតាមមើលសកម្មភាព (អនឡាញនិងមិនអនឡាញ) របស់សមាជិកនៃក្រុម CALD
- ដើម្បីឃោសនាអំពីទស្សនៈនិងគោលនយោបាយរបស់រដ្ឋាភិបាលបរទេសនោះ
- ដើម្បីយកព័ត៍មានសម្រាប់ភាពចំណេញរបស់រដ្ឋាភិបាលបរទេសនោះ
- ដើម្បីជះឥទ្ធិពលលើទស្សនៈនិងយោបល់របស់ប្រជាពលរដ្ឋជាទូទៅ

## ការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍អាចមានច្រើនសណ្ឋាន

រួមទាំង ៖

- ការវាយតប់ ឬការគម្រាមថានឹងវាយតប់
- ការកៀបដើម្បីឲ្យជនរងគ្រោះធ្វើអ្វីមួយ
- ការចាប់ជំរិត ការឃុំឃាំងខុសច្បាប់ ឬការបង្អត់សេរីភាព

- ការលបមើល និងការឃ្លាំមើលដោយផ្ទាល់ឬតាមប្រព័ន្ធអេឡិចត្រូនិចដែលគ្មានអ្នកណាចង់បាន
- ការកៀបសង្កត់បុគ្គលម្នាក់តាមការគម្រាមគ្រួសារឬគ្នាខ្ចនៅបរទេសរបស់បុគ្គលនោះដើម្បីបង្ខំឲ្យបុគ្គលនោះធ្វើតាមអ្វីដែលពួកគេចង់បាន
- ការផ្សព្វផ្សាយតាមអនឡាញនូវព័ត៌មានមិនពិតដើម្បីបង្ខូចឈ្មោះបុគ្គលណាម្នាក់ឬក្រុមណាមួយ។

ជាកត្តាសំខាន់ ដើម្បីរាប់បានជាការជ្រៀតជ្រែកពីបរទេសក្រោមច្បាប់ឆ្នាំ ១៩៩៥ សកម្មភាពនោះត្រូវតែមានភ្ជាប់ជាមួយរដ្ឋាភិបាលបរទេសមួយ ឬក៏តំណាងរបស់ប្រទេសនោះ។ ក្នុងការវាយតម្លៃអំពីឧក្រិដ្ឋភាព អាជ្ញាធរមានសមត្ថកិច្ចអាចពិចារណាផងដែរថាវាជាបទល្មើសនៅក្នុងរដ្ឋឬដែនដីអូស្ត្រាលី។

## តើគេសំដៅអ្នកណាខ្លះ ?

រដ្ឋាភិបាលបរទេសអាចសំដៅចំពោះ ៖

- ជនដែលពីមុនឬបច្ចុប្បន្នមានសញ្ជាតិប្រទេសនោះហើយកំពុងរស់នៅប្រទេសអូស្ត្រាលី
- សកម្មជននយោបាយនិងសិទ្ធិមនុស្ស
- អ្នកប្រឆាំង
- អ្នកសារព័ត៌មាន
- អ្នកមកពីគណបក្សប្រឆាំង
- ក្រុមសាសនាឬជនជាតិភាគតិច

## តើខ្ញុំអាចធ្វើអ្វីដើម្បីជួយ ?

ទោះបីមិនមែនការរាយការណ៍អំពីការជ្រៀតជ្រែកពីបរទេសទាំងអស់សុទ្ធតែបង្កើតឲ្យមានការឆ្លើយតបជានិច្ចពី AFP នោះទេ ប៉ុន្តែការរាយការណ៍និមួយៗ**ជួយក្នុងការបង្កើតបានរូបភាព**របស់បញ្ហាទាំងឡាយដែលកំពុងលេចចេញឡើង។

ចំពោះការបារម្ភនានា និង/ឬ ហេតុការណ៍នានានៃការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍ គេអាចធ្វើការរាយការណ៍ទៅ **National Security Hotline (NSH)** (ទូរសព្ទជាប្រចាំសម្រាប់សន្តិសុខជាតិ)

- NSH ធ្វើការ ២៤ម៉ោងក្នុង១ថ្ងៃ ៧ ថ្ងៃក្នុង១សប្តាហ៍ ហើយជាចំណុចទំនាក់ទំនងកណ្តាលសម្រាប់ការរាយការណ៍អំពីការបារម្ភថាអាចមានការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍។
- ទូរសព្ទការីរបស់ NSH នឹងដឹងថាត្រូវធ្វើអ្វីជាមួយនិងព័ត៌មានដែលលោកអ្នកផ្តល់ ហើយបើសមស្រប ពួកគេនឹងបញ្ជូនទៅអាជ្ញាធរច្បាប់និងភ្នាក់ងារសន្តិសុខដើម្បីធ្វើការវាយតម្លៃ។
- ទូរសព្ទការីរបស់ NSH គិតការហៅចូលនិមួយៗថាមិនមែនជារឿងលេងៗទេ ហើយផ្តល់តម្លៃដល់គ្រប់ព័ត៌មានទាំងអស់ដែលពួកគេទទួល។
- យើងដឹងថា ការរាយការណ៍អំពីរឿងដែលគួរឲ្យបារម្ភអាចជាជំហានធំមួយ។ យើងមានគោលការណ៍ដ៏ហ្មត់ចត់ថាអ្នកមានសិទ្ធិស្ថិតក្នុងភាពសម្ងាត់។ សូមប្រាប់ទៅទូរសព្ទការីប្រសិនបើអ្នកចង់ស្ថិតនៅជាអនាមិក។
- ដោយសារភាពរសើបនៃព័ត៌មានទាំងនោះ លោកអ្នកនឹងមិនទទួលបានការផ្តល់ដំណឹងអំពីលទ្ធផលនៃការហៅទូរសព្ទឬអ៊ីមែលរបស់លោកអ្នកនោះទេ។

ព័ត៌មានដែលអ្នកផ្តល់អាចជាព័ត៌មានដែល AFP នៅខ្វះ
ហើយត្រូវការវាដើម្បីជួយទប់ស្កាត់ការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍។

មានផ្លូវពីរបីយ៉ាងក្នុងការទាក់ទងជាមួយ **NSH** ៖

- **ទូរសព្ទទៅលេខ 1800 123 400**
  - ហៅពីក្រៅអូស្ត្រាលី : (+61) 1300 123 401
  - សម្រាប់អ្នកប្រើ TTY (អ្នកមានពិការភាពត្រចៀក) : 1800 234 889
  - **ប្រសិនបើអ្នកត្រូវការអ្នកបកប្រែ សូមទូរសព្ទទៅសេវាបកប្រែលេខ 131 450 ហើយសុំឱ្យគេហៅទៅ National Security Hotline**
- **SMS** (សារតាមទូរសព្ទ)
  - សូមបញ្ជូនព័ត៌មានរបស់អ្នកជាអក្សរទៅលេខ 0429 771 822
- **អ៊ីមែល**
  - សូមបញ្ជូនព័ត៌មានរបស់អ្នកតាមអ៊ីមែលទៅ hotline@nationalsecurity.gov.au
- **ប្រៃសណីយ៍**
  - សូមផ្ញើសំបុត្រព័ត៌មានរបស់អ្នកទៅ ៖

    National Security Hotline
    Department of Home Affairs
    PO Box 25
    Belconnen ACT 2616

## របៀបដទៃទៀតក្នុងការធ្វើការរាយការណ៍

លោកអ្នកអាចរាយការណ៍អំពីការបារម្ភរបស់លោកអ្នកតាមមធ្យោបាយមួយចំនួនច្រើនទៀត បើសមស្រប។

- eSafety ជួយដកចេញ ព័ត៌មានដែលអាក្រក់ធ្ងន់ធ្ងរតាមអនឡាញ។
  លោកអ្នកអាចរាយការណ៍អំពីការប្រើ**អនឡាយខុសធ្ងន់ធ្ងរ**ទៅស្ថងការនៃ eSafety នៅ esafety.gov.au/report.
- ប្រសិនបើអ្នក**មានអារម្មណ៍ថាមានគេគម្រាម** ឬមិនមានសុវត្ថិភាពក្នុងសណ្ឋានណាមួយ អ្នកអាចទាក់ទងទៅ ៖
  - **ប៉ូលិស - តាមលេខ 000 សម្រាប់ការគម្រាមភ្លាមៗ**
  - **ប៉ូលិស - តាមលេខ 13 14 44 សម្រាប់ឲ្យប៉ូលិសមកកន្លែងកើតហេតុដែលមិនបង្កគ្រោះថ្នាក់ដល់ជីវិត។**
- អ្នកអាចរាយការណ៍អំពីឧក្រិដ្ឋកម្មសហធនទៅ AFP តាមទម្រង់បែបបទ “Report a Commonwealth Crime” អនឡាញនៅ forms.afp.gov.au/online_forms/report_a_crime។
  ចំពោះព័ត៌មានបន្ថែមទៀតស្តីអំពីអ្វីដែលរាប់ជាឧក្រិដ្ឋកម្មសហធន សូមមើល afp.gov.au/contact-us/report-commonwealth-crime#What-is-a-Commonwealth-crime.
- សមាជិកណាមួយក៏ដោយក្នុងសហគមន៍ អាចរាយការណ៍អំពីការសង្ស័យថាមានចារកម្ម ឬសកម្មភាពជ្រៀតជ្រែកពីបរទេស ដោយនិយាយផ្ទាល់ជាមួយសមាជិកនៃ AFP (រួមទាំងក្រុមទំនាក់ទំនងសហគមន៍របស់ AFP)។

## តើខ្ញុំអាចនឹករំពឹងថានឹងឃើញអ្វីកើតឡើងដោយការរាយការណ៍អំពីការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍ ?

AFP មិនអាចស៊ើបអង្កេតរាល់របាយការណ៍អំពីការជ្រៀតជ្រែកពីបរទេសក្នុងសហគមន៍ទេ។ រាល់ការហៅទូរសព្ទទៅ AFP ឬរបាយការណ៍អំពីឧក្រិដ្ឋកម្ម ត្រូវបានវាយតម្លៃតាមករណីនិមួយៗដើម្បីបញ្ជាក់ថា តើមានបទល្មើសឧក្រិដ្ឋដែរឬអត់។ លទ្ធផលនៃការរាយការណ៍ រួមមាន ៖

- វាអាចមិនមានការឆ្លើយតបដោយសាររឿងរ៉ាវនោះមិនដល់កម្រិតច្បាប់ដែលប៉ូលិសត្រូវចាត់វិធានការណ៍
- AFP អាចធ្វើការស៊ើបអង្កេត
- មានប៉ូលិសផ្នែកមួយទៀត ឬស្ថាប័នរដ្ឋាភិបាលមួយទៀត ចាត់ចែងរឿងនោះ។

សម្រាប់បទល្មើសនានានៅក្រៅប្រទេសអូស្ត្រាលី យើងអនុវត្តតាមការកំណត់ដែនសមត្ថកិច្ចយុត្តាធិការ។

## ប្រភេទនៃការគម្រាមកំហែង

### ប្រសិនបើអ្នកត្រូវបានគេគម្រាមដោយផ្ទាល់

- ចូរសរសេរ ឬកត់អំពីការគម្រាមនោះឲ្យដូចអ្វីៗដែលគេបាននិយាយ/ធ្វើសញ្ញា។
- កត់ចំណុចលំអិតឲ្យបានច្រើនអំពីជនដែលធ្វើការគម្រាមនោះ(ឈ្មោះ ភេទ កំពស់ ទម្ងន់ ពណ៌ភ្នែកនិងសក់ សម្លេង ខោអាវ ឬក៏ភិនភាគចម្លែកទាំងឡាយ)។
- រាយការណ៍អំពីការគម្រាមនោះទៅប៉ូលិស។

### ប្រសិនបើអ្នកត្រូវបានគេគម្រាមតាមទូរសព្ទ

- បើអាច ធ្វើសញ្ញាទៅអ្នកដទៃដែលនៅក្បែរឲ្យស្ដាប់និងប្រាប់ប៉ូលិស។
- ថតសម្លេងក្នុងទូរសព្ទ បើអាច។
- សរសេរពាក្យទាំងឡាយឲ្យដូចដែលគេនិយាយគម្រាមនោះ។
- ចម្លងព័ត៌មានទាំងឡាយណាដែលមានក្នុងអេក្រង់អេឡិចត្រូនិចរបស់ទូរសព្ទ។
- រកពេលសម្រាប់ពិភាក្សាលំអិតជាមួយប៉ូលិស។

### ប្រសិនបើអ្នកត្រូវបានគេគម្រាមតាមមធ្យោបាយអេឡិចត្រូនិច រួមទាំងតាមសារទូរសព្ទ សារផ្ទាល់/ឯកជន បណ្ដាញសង្គម ឬអ៊ីមែល

- ចូរកុំលុបសារទាំងនោះចេញ
- ព្រីន ថតរូប ចុចថតទុក (screenshot ) ឬចម្លងទុកព័ត៌មានក្នុងសារនោះ (ប្រធានបទ ថ្ងៃខែ ម៉ោង អ្នកផ្ញើ ។ល។)។ សុំឲ្យប្រាកដថាអ្នកផ្ដកឬចុចថតទុកសារទាំងឡាយណាដែលគេបង្កើតសម្រាប់តែប្រើបណ្ដោះអាសន្ន។
- ប្រាប់ទៅប៉ូលិសភ្លាមថាអ្នកទទួលបានការគម្រាម។
- រក្សាទុកភស្តុតាងអេឡិចត្រូនិចទាំងអស់។

**ដើម្បីការពារខ្លួនអ្នកពីការគម្រាមប្រភេទទាំងនេះ សូមធ្វើតាមយោបល់ខាងក្រោមនេះ ៖**

- កុំបើកសារអេឡិចត្រូនិច ឬឯកសារភ្ជាប់មកជាមួយ ពីអ្នកដែលយើងមិនស្គាល់
- កុំប្រាស្រ័យទាក់ទងក្នុងបណ្តាញសង្គមជាមួយបុគ្គលដែលអ្នកមិនស្គាល់ ឬដែលអ្នកមិនបានហៅរក
- សុំឲ្យច្បាស់ថា
  កម្រិតសន្តិសុខក្នុងឧបករណ៍/គណៈនេយ្យរបស់អ្នកត្រូវបានដាក់ឲ្យមានការការពារខ្ពស់បំផុត
- ឧក្រិដ្ឋ ជនតាមកុំព្យូទ័រនិងអ៊ិនធើណិតអាចធ្វើឲ្យសន្តិសុខនៃឧបករណ៍អេឡិចត្រូនិចរបស់អ្នក
  មិនសូវមាំទាំ ហើយធ្វើឲ្យគេឃើញព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក
- ទាក់ទងទៅស្ថាប័នហិរញ្ញវត្ថុរបស់អ្នកភ្លាមដើម្បីការពារគណៈនេយ្យរបស់អ្នកកុំឲ្យគេលួចអត្តសញ្ញាណ
- ប្រើឃ្លាសម្ងាត់ដែលមាំ ហើយកុំប្រើឃ្លាសម្ងាត់ដដែលៗនោះសម្រាប់វែបសាយច្រើន
- ធ្វើយ៉ាងណាឲ្យកម្មវិធីប្រឆាំងវីរុស និងប្រឆាំងកម្មវិធីបំផ្លាញកុំព្យូទ័រ មានធ្វើបច្ចុប្បន្នភាព
- ធ្វើឲ្យប្រព័ន្ធ និងប្រូក្រាម មានបច្ចុប្បន្នភាពតាមការតម្រូវ
- អនុវត្តការបញ្ជាក់អត្តសញ្ញាណតាមរយៈ២កត្តា
- ផ្ទុកបំរុង(Backup)ទិន្នន័យជាប្រចាំ
- ធ្វើឲ្យឧបករណ៍ចល័តរបស់អ្នក មានសន្តិសុខមាំទាំ
- បណ្តុះបណ្តាលគំនិត និងការយល់ដឹងរបស់អ្នកអំពីសន្តិសុខនៃកុំព្យូទ័រនិងអ៊ិនធើណិត
- សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ cyber.gov.au.